ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមព្រហ្មទណ្ឌ
លេខ: ៥៩០ "ដក្រ៦"
ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០
-សំណុំរឿងព្រហ្មទណ្ឌលេខ:៨៥៥២
ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៩
-សំណុំរឿងស៊ើបសួរលេខ:៥៨៣៤
ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៩
-សំណុំរឿងជំនុំជម្រះលេខ:១១១០
ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០

សាលក្រម
នាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅសាលជំនុំជម្រះទី៥នៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ដោយមានសមាសភាពអង្គជំនុំជម្រះដូចតទៅ៖

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ:៨៥៥២ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ជាន់និត ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅ[redacted]ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិព្រែកពពេល ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] អឿន "រ" ម្តាយឈ្មោះ [redacted] ទូច "រ" ជានីតិជន ទោសពីមុនគ្មាន។ ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ១៤៤៤៦ "ឈ" ដ.ឃ.ដ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៩។

២-ឈ្មោះ [redacted] រើន ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរកម្មករ ទីកន្លែងកំណើត[redacted]ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិគល់ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ន្នន "រ" ម្តាយឈ្មោះ [redacted] សាវ៉ែត "រ" ជានីតិជន ទោសពីមុនគ្មាន ដែលមានក្នុងដីកាបង្គាប់ឲ្យឃុំលេខ ១៤៤៤៥ "ឈ" ដ.ឃ.ដ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៩។

៣-ឈ្មោះ [redacted] សាវឡុង ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត[redacted]ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិបុរីកម្មករ

ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល នៅលីវ ឪពុកឈ្មោះ [redacted] រស់ "រ" ម្តាយឈ្មោះ [redacted] សម្ផស្ស "រ" ជា ទីតិជន ទោសពីមុនគ្មាន។ (គេចខ្លួន)

ជាប់ចោទពីបទ: លួចមានស្ថានទម្ងន់ទោស (វាយឈរម៉ូតូ) ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវជាតិ លេខ៤ ភូមិព្រៃបឹង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ តាមបញ្ញត្តិ មាត្រា៣៥៣ មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទ ឈ្មោះ [redacted] ផាន់ធិត ឈ្មោះ [redacted] រើន ឈ្មោះ [redacted] សាវឡុង។

-ជនរងគ្រោះឈ្មោះ [redacted] ចិត្រា ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិព្រៃ ឈើទាល ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

អត្ថហេតុនៃរឿងមានដូចតទៅ

តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ដីកាសន្និដ្ឋានស្តាពររបស់តំណាងអយ្យការអមសាលា ដំបូងរាជធានីភ្នំពេញ និងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានី ភ្នំពេញបានកំណត់នូវអង្គហេតុនៃរឿងដូចតទៅ៖

កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ ជនរងគ្រោះឈ្មោះ [redacted] ចិត្រា បានជិះម៉ូតូឌុបប្អូនចេញពីឃ្លាំងនៅ ភូមិតាងួន មកតាមបណ្តោយផ្លូវជាតិលេខ៤ ភូមិព្រៃបឹង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ សំដៅមកទី ស្នាក់ការក្រុមហ៊ុននៅម្តុំផ្លូវ២០០៤ ក៏បានជួបជនចោទជាប់ឈ្មោះ [redacted] ផាន់ធិត ឈ្មោះ [redacted] រើន ឈ្មោះ [redacted] សាវឡុង និងបក្ខពួក ហើយពួកនោះបានធ្វើសកម្មភាពធាក់ម៉ូតូរបស់ជនរងគ្រោះផ្តួលហើយដណ្តើមយកម៉ូតូជនរងគ្រោះ ជិះគេចខ្លួនក្រោយពេលកើតហេតុហើយជនរងគ្រោះក៏ទៅដាក់ពាក្យបណ្តឹងនៅនគរបាលប៉ុស្តិ៍រដ្ឋបាលកន្ទោកហើយ សមត្ថកិច្ចបានស្រាវជ្រាវឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ផាន់ធិត ឈ្មោះ [redacted] រើន ចាត់ការទៅតាមច្បាប់។

-បានឃើញរបាយការណ៍សំយោគលេខ០០៦/១៩ រ.ប.ក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ របស់អធិការដ្ឋាន នគរបាលខណ្ឌកំបូល។

-បានឃើញដីកាសន្និដ្ឋានស្តាពរលេខ ៨៣៦ អ.យ.ឈ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ របស់តំណាង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ១០៥៩ "ខ១" ដ.ដ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] រើន បានឆ្លើយថា: កាលពីថ្ងៃកើតហេតុខ្លួនចេញពីដើរលេងមានគ្នាច្រើន ប្រហែល១០ម៉ូតូ ក្រោយមកបែកគ្នាទៅផ្ទះរៀងៗខ្លួននៅសល់តែបីម៉ូតូ។ ពេលនោះឈ្មោះ [redacted] ផាន់ធិត ជាអ្នកធាក់ ម៉ូតូគេផ្តួលខ្លួនជិះនៅខាងក្រោយពេល [redacted] ផាន់ធិត ចុះទៅលើកយកម៉ូតូគេជិះចេញទៅខ្លួនភ័យក៏ជិះម៉ូតូដែលឈ្មោះ

[redacted] ជាន់និត ឧបខ្លួននោះជិះចេញទៅដែរ។ ពេលធ្វើសកម្មភាពនោះមានតែពីរនាក់ ខ្លួននិងឈ្មោះ [redacted] ជាន់និត នៅវេលាម៉ោងប្រហែល ១២ឃប់ ខ្លួនពុំមានគំនិតចូលរួមធាក់ម៉ូតូរបស់គេក្នុងគោលបំណងយកម៉ូតូរបស់គេទេ ដោយខ្លួនពុំបានដឹងពីគំនិតរបស់ឈ្មោះ [redacted] ជាន់និត ធាក់គេយកម៉ូតូរបស់គេនោះទេ។

-ជនជាប់ចោទឈ្មោះ [redacted] ជាន់និត បានឆ្លើយថា: ចំពោះចម្លើយដែលឈ្មោះ [redacted] រើន និយាយនេះជាចម្លើយពិត។ ចំពោះឈ្មោះ ឡុង ជាមិត្តភក្តិរបស់ខ្លួនគាត់បានទូរស័ព្ទប្រាប់ខ្លួនថា គេវាយប្អូនគាត់ខ្លួនក៏ដេញតាមធាក់ម៉ូតូនោះផ្តួល ពេលនោះមានគ្នា៦នាក់ ម៉ូតូបីគ្រឿង។ ពេលខ្លួនធាក់ម៉ូតូដួលហើយជនរងគ្រោះរត់ចោលម៉ូតូចូលទៅក្នុងការ៉ាស់សាំង ដោយពួកខ្លួនដេញវាយ ហើយគេជិះចោលខ្លួនអស់ទើបខ្លួនលើកម៉ូតូរបស់ជនរងគ្រោះជិះចេញទៅហើយពួកខ្លួនស្រែកអោយជិះម៉ូតូជនរងគ្រោះទៅជួបគ្នានៅមុខមន្ទីរពេទ្យយកទៅអោយឈ្មោះ ឡុង ជាអ្នកយកទៅលក់ ពេលលក់បានហើយឈ្មោះ ឡុង អោយខ្លួន ៥០ (ហាសិប)ដុល្លាអាមេរិក។ ខ្លួនទទួលយកចម្លើយដែលខ្លួនបានឆ្លើយនៅចំពោះមុខតំណាងអយ្យការ នៅចៅក្រមស៊ើបសួរ និងចម្លើយនៅពេលសវនាការនេះ ចំពោះចម្លើយនៅសមត្ថកិច្ចខ្លួនពុំទទួលយកទេ។

-តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ចិត្រា ថា: កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល២ឃប់ខ្លួនជិះម៉ូតូចេញពីឃ្លាំងនៅភូមិតាងួន គោលបំណងទៅស្នាក់ការក្រុមហ៊ុននៅម្តុំផ្លូវ២០០៥ លុះពេលខ្លួនជិះម៉ូតូចេញពីក្រុមហ៊ុនបានបន្តិចក៏បានជួបនឹងមនុស្សពីរនាក់ជិះម៉ូតូមួយគ្រឿង ម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៤ គួរអោយសង្ស័យ ព្រោះពួកវានេះតែងសម្លឹងមើលខ្លួន ពេលនោះដោយមានការសង្ស័យខ្លួនក៏ជិះយ៉ាងលឿនទៅទិសខាងកើត ហើយជនពីរនាក់ជិះម៉ូតូមួយគ្រឿងម៉ាកសង់ (២០១៤) បានជិះតាមពីក្រោយខ្លួនរហូតលុះដល់ចំណុចមុខការ៉ាស់សាំងតេឡា ភូមិផ្សារកំបូល ជនពីរនាក់ជិះម៉ូតូមួយគ្រឿងម៉ាក ហុងដា (២០១៨) បានធាក់ម៉ូតូខ្លួនផ្តួល រួចខ្លួនបំរុងលើកម៉ូតូជិះ ស្រាប់តែបក្ខពួកវាម៉ូតូមួយគ្រឿងហុងដា (២០១៤) គ្នាពីរនាក់ដែលបានជួបលើកមុនដំបូងនោះវាលូកយករបស់អ្វីពីក្នុងអាវបំរុងកាប់ខ្លួនរួចខ្លួនក៏រត់ចោលម៉ូតូហើយស្រែកអោយគេជួយចំណែកពួកវាជិះម៉ូតូគេចខ្លួនបាត់ទៅ។

ម៉ូតូរបស់ខ្លួនម៉ាក ហុងដា សេ១២៥ ពណ៌ខ្មៅ (២០១៨) ពាក់ស្លាកលេខកំពង់ស្ពឺ ១I-៤៨៤៩ មិនចាំលេខតួ លេខម៉ាស៊ីន ពីព្រោះកាតគ្រីមិនយកតាមខ្លួន ជាកម្មសិទ្ធិរបស់ខ្លួនទិញបង់រំលោះពីក្រុមហ៊ុន។ ខ្លួនសូមអោយសមត្ថកិច្ចជួយស្រាវជ្រាវដើម្បីផ្តន្ទាទោសជនល្មើសទៅតាមច្បាប់។

<u>សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ</u>

-តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការ និងពិនិត្យភស្តុតាងក្នុងសំណុំរឿងឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើល្មួចមានស្ថានទម្ងន់ទោស ពិតប្រាកដមែន។

ក្នុងនាមជាតំណាងអយ្យការ ខ្ញុំនៅរក្សាបទចោទប្រកាន់ដូចមាន ក្នុងដីកាសន្និដ្ឋានស្តារពរលេខ ៨៣៦ អ.ឃ.ឈ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ

ដដែលនិងប្តឹងសុំអោយតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

<u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិអោយជនជាប់ចោទ</u>

-មេធាវីការពារសិទ្ធិអោយជនជាប់ចោទលោកមេធាវី [redacted] និងលោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីរបស់ខ្ញុំបានឆ្លើយសារភាពទទួលស្គាល់នូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តរួចអស់ហើយ ម្យ៉ាងទៀតកូនក្តីរបស់ខ្ញុំទាំងបីនាក់នេះមានកំរិតវប្បធម៌ទាបពុំចេះពិចារណាវែងឆ្ងាយនូវផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួន។

ក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទ ខ្ញុំសំណូមពរសុំអោយតុលាការពិចារណាពីស្ថានសម្រាលទោសអោយកូនក្តីរបស់ខ្ញុំដោយក្តីអនុគ្រោះ។

<u>សម្តីចុងក្រោយរបស់ជនជាប់ចោទ</u>

-ជនជាប់ចោទឈ្មោះ [redacted] ផាន់និត និងឈ្មោះ [redacted] រើន បានសំណូមពរដល់តុលាការជាសំដីចុងក្រោយបង្អស់ថា សុំតុលាការបន្ធូរបន្ថយទោសអោយខ្លួនផង។

-ក្រោយពីបានស្តាប់ចំលើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានា

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>សំអាងហេតុ</u>

អំពីអង្គហេតុនៃការចោទប្រកាន់លើឈ្មោះ [redacted] រើន ឈ្មោះ [redacted] ផាន់និត និងឈ្មោះ [redacted] សាវឡុច

១/ ឃល់ឃើញថាជនជាប់ចោទឈ្មោះ [redacted] រើន ឈ្មោះ [redacted] ផាន់និត និងឈ្មោះ [redacted] សាវឡុង ត្រូវបានចោទប្រកាន់ទៅតាមអង្គហេតុទាំងឡាយនៃការទទួលខុសត្រូវរបស់ពួកគាត់ដែលមាននៅក្នុងដីកាសន្និដ្ឋានស្តាពរលេខ៨៣៦អយឈ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ១០៥៩ (ខ១) ដ.ដ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ដូចមានចែងក្នុងមាត្រា៣៥៣ មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ចំពោះអំពើទាំងឡាយដែលបានកើតឡើងកាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ នៅចំណុចតាមបណ្តោយផ្លូវជាតិលេខ៤ ភូមិព្រៃបឹង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ។

២/ឃល់ឃើញថាជនជាប់ចោទឈ្មោះ [redacted] រើន និងឈ្មោះ [redacted] ផាន់និត និងឈ្មោះ [redacted] សាវឡុង ត្រូវ

ចោទប្រកាន់ថារូបគាត់មានចេតនាលួចមានស្ថានទម្ងន់ទោស ដែលជាអំពើផ្ទុយជាមួយច្បាប់ហើយបង្ហាញអោយឃើញនូវសកម្មភាពរួមគ្នាក្នុងការចាត់ចែងប្រើហិង្សាមកលើជនរងគ្រោះ ដណ្តើមយកម៉ូតូពីជនរងគ្រោះហើយជិះគេចខ្លួនដែលអំពើរបស់ជនជាប់ចោទនេះ វាធ្វើអោយប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ របៀបរៀបរយនិងសណ្តាប់ធ្នាប់សង្គមដែលកើតចេញពីអំពើដោយផ្ទាល់របស់ជនជាប់ចោទ ហើយត្រូវបានដាក់អោយទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនៃបទលួចមានស្ថានទម្ងន់ទោសដែលបានចោទប្រកាន់ប្រឆាំងនិងជនជាប់ចោទដោយអនុលោមតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អំពីអង្គហេតុនាក់ទងនិងបទលួចមានស្ថានទម្ងន់ទោស

៣/តុលាការពិនិត្យឃើញថា កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ សមត្ថកិច្ចបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] **រើន** និងឈ្មោះ [redacted] **ជាន់និត** ដែលពាក់ព័ន្ធក្នុងករណីរួមគ្នាវាយជនរងគ្រោះដណ្តើមយកម៉ូតូនៅចំណុចតាមបណ្តោយផ្លូវជាតិលេខ៤ ស្ថិតនៅភូមិព្រៃបឹង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ។

៤/ទាក់ទងនិងអំពើលួចមានស្ថានទម្ងន់ទោស ដែលជាអំពើមានគោលដៅប្រឆាំងទៅនិងទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ពលរដ្ឋដែលត្រូវបានធានាដោយរដ្ឋក្នុងកិច្ចការពារកម្មសិទ្ធិស្របច្បាប់របស់ពលរដ្ឋហើយសកម្មភាពរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោសវាបានចូលរួមក្នុងការបំផ្លាញសង្គមជាតិតាមរយៈសំដីជនជាប់ចោទ និងជនរងគ្រោះដែលបានឆ្លើយនូវពេលសវនាការដូចតទៅ៖

-ជនជាប់ចោទឈ្មោះ [redacted] **រើន** បានឆ្លើយថា: កាលពីថ្ងៃកើតហេតុខ្លួនចេញពីដើរលេងមានគ្នាច្រើនប្រហែល១០ម៉ូតូក្រោយមកបែកគ្នាទៅផ្ទះរៀងៗខ្លួននៅសល់តែបីម៉ូតូ។ ពេលនោះឈ្មោះ [redacted] **ជាន់និត** ជាអ្នកធាក់ម៉ូតូគេផ្តួលខ្លួនជិះពីក្រោយ ពេលដែល [redacted] **ជាន់និត** ចុះទៅលើកយកម៉ូតូគេជិះចេញទៅ ខ្លួនភ័យក៏ជិះម៉ូតូដែលឈ្មោះ [redacted] **ជាន់និត** ឧបខ្លួននោះជិះចេញទៅដែរ។ ពេលធ្វើសកម្មភាពមានតែពីរនាក់ខ្លួននិងឈ្មោះ [redacted] **ជាន់និត** នៅវេលាម៉ោងប្រហែល១២ឃប់ ខ្លួនពុំមានគំនិតចូលរួមធាក់ម៉ូតូរបស់គេក្នុងគោលបំណងយកមកម៉ូតូគេទេដោយខ្លួនពុំបានដឹងពីគំនិតរបស់ឈ្មោះ [redacted] **ជាន់និត** ដែលធាក់គេកំពុងជិះម៉ូតូអោយដួលរួចដណ្តើមយកម៉ូតូរបស់គេជិះចេញទៅនោះទេ។

-ជនជាប់ចោទឈ្មោះ [redacted] **ជាន់និត** បានឆ្លើយថា: ចំពោះចម្លើយដែលឈ្មោះ [redacted] **រើន** និយាយនោះជាចម្លើយពិត។ ចំពោះឈ្មោះ [redacted] **សាវឡុង ហៅ ឡុង** ជាមិត្តភ័ក្ត្រខ្លួនគាត់បានទូរស័ព្ទប្រាប់ខ្លួនថា គេវាយប្អូនគាត់ខ្លួនក៏ដេញតាមធាក់ម៉ូតូនោះផ្តួល ពេលនោះមានគ្នា៦នាក់ម៉ូតូបីគ្រឿង។ ពេលខ្លួនធាក់ម៉ូតូដួលហើយ ជនរងគ្រោះរត់ចោលម៉ូតូចូលទៅក្នុងការ៉ាសសាំង ដោយពួកខ្លួនដេញវាយហើយគេជិះចោលខ្លួនអស់ ទើបខ្លួនលើកម៉ូតូរបស់ជនរងគ្រោះជិះចេញទៅ ហើយពួកខ្លួនស្រែកអោយជិះម៉ូតូជនរងគ្រោះទៅជួបគ្នានៅមុខមន្ទីរពេទ្យ យកទៅអោយឈ្មោះ [redacted] **សាវឡុង ហៅ ឡុង** ជាអ្នកយកទៅលក់ ពេលលក់បានហើយឈ្មោះ ឡុង អោយខ្លួន៥០ដុល្លារអាមេរិក តែខ្លួនពុំយក។

ខ្លួនទទួលយកចម្លើយដែលខ្លួនបានឆ្លើយនៅចំពោះមុខតំណាងអយ្យការ នៅចៅក្រមស៊ើបសួរនិងចម្លើយ

នៅពេលសវនាការនេះ ចំពោះចម្លើយនៅសមត្ថកិច្ចពុំទទួលយកទេ។

-តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ចិត្រា ថាកាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល២ឃប់ ខ្លួនជិះម៉ូតូចេញពីឃ្លាំងនៅភូមិតាងួន គោលបំណងទៅស្នាក់ការក្រុមហ៊ុននៅម្តុំផ្លូវ២០០៤ លុះពេលខ្លួនជិះម៉ូតូចេញពីក្រុមហ៊ុនបានបន្តិច ក៏បានជួបនឹងមនុស្សពីរនាក់ជិះម៉ូតូមួយគ្រឿងម៉ាកហុងដា C១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៤ គួរអោយសង្ស័យព្រោះពួកវានេះតែងសម្លឹងមើលខ្លួន ពេលនោះដោយមានការសង្ស័យខ្លួនក៏ជិះយ៉ាងលឿនទៅទិញខាងកើត ហើយជនពីរនាក់ជិះម៉ូតូមួយគ្រឿងម៉ាកសង់ (២០១៤) បានជិះតាមពីរក្រោយខ្លួនរហូត លុះដល់ចំណុចមុខការ៉ាស់សាំងតេឡា ភូមិផ្សារកំបូល ជនពីរនាក់ជិះម៉ូតូមួយគ្រឿងម៉ាក HONDA (២០១៨) បានធាក់ម៉ូតូខ្លួនផ្តួល រួចខ្លួនបំរុងលើកម៉ូតូជិះស្រាប់តែបក្ខពួកវា ម៉ូតូមួយគ្រឿងម៉ាកហុងដា(២០១៤) គ្នាពីរនាក់ដែលបានជួបលើកមុនដំបូងនោះវាលូកឈករបស់អ្វីពីក្នុងអាវបំរុងកាប់ខ្លួន រួចខ្លួនក៏រត់ចោលម៉ូតូ ហើយស្រែកអោយគេជួយ ចំណែកពួកវាជិះម៉ូតូគេចខ្លួនបាត់ទៅ។

ម៉ូតូរបស់ខ្លួនម៉ាក HONDA សេ១២៥ ពណ៌ខ្មៅ (២០១៨) ពាក់ស្លាកលេខ កំពង់ស្ពឺ ១I-៤៨៤៩ មិនចាំលេខតួ លេខម៉ាស៊ីន ពីព្រោះកាតគ្រីមិនយកតាមខ្លួនជាកម្មសិទ្ធិរបស់ខ្លួនទិញបង់រំលស់ពីក្រុមហ៊ុន។ ខ្លួនសូមអោយសមត្ថកិច្ចជួយស្រាវជ្រាវដើម្បីផ្តន្ទាទោសជនល្មើសទៅតាមច្បាប់។

៥/តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **រើន** , ឈ្មោះ [redacted] **ផាន់និត** និងចម្លើយជនរងគ្រោះឈ្មោះ [redacted] ចិត្រា ឆ្លើយមកមានភាពស៊ីសង្វាក់គ្នា ដែលបញ្ជាក់អោយឃើញពីសកម្មភាពរបស់ជនជាប់ចោទឈ្មោះ **យ៉ុន ផាន់និត** ជិះម៉ូតូម៉ាក HONDA សេរីឆ្នាំ២០១៨ ឌុបជនជាប់ចោទឈ្មោះ [redacted] **រើន** ជិះដេញតាមម៉ូតូជនរងគ្រោះឈ្មោះ [redacted] ចិត្រា ដែលជិះឌុបប្អូនប្រុស ហើយជនជាប់ចោទឈ្មោះ [redacted] **ផាន់និត** ធាក់ម៉ូតូជនរងគ្រោះអោយដួលហើយសម្គុតជនរងគ្រោះពេលនោះជនរងគ្រោះនិងប្អូនប្រុសក៏រត់ចូលក្នុងការ៉ាស់សាំងតេឡា ទើបជនជាប់ចោទឈ្មោះ [redacted] **ផាន់និត** មកយកម៉ូតូជនរងគ្រោះជិះគេចខ្លួន ចំណែកជនជាប់ចោទឈ្មោះ [redacted] **រើន** ក៏ជិះម៉ូតូចេញតាមគ្នាដែរ។ ទោះបីជនជាប់ចោទឈ្មោះ [redacted] **រើន** ឆ្លើយនៅពេលសវនាការថា ខ្លួនពុំដឹងពីគោលបំណងរបស់ជនជាប់ចោទឈ្មោះ [redacted] **ផាន់និត** ដែលជិះតាមធាក់ផ្តួលម៉ូតូរបស់ជនរងគ្រោះ ហើយយកម៉ូតូរបស់ជនរងគ្រោះជិះចេញទៅក៏ដោយ ក៏គ្មានភស្តុតាងដោះបន្ទុកដែរ ដោយជនជាប់ចោទខ្លួនឯងបានឆ្លើយនៅសមត្ថកិច្ចថា សកម្មភាពនេះមានការរៀបចំដោយឈ្មោះ [redacted] **សាវឡុង ហៅ ឡុង** ជាមេក្លោង។

តាមអង្គហេតុដែលបានកើតឡើងនិងចំលើយរបស់ជនជាប់ចោទ ចំលើយជនរងគ្រោះជាមួយរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងនានាដែលប្រមូលបានមានភាពស៊ីសង្វាក់គ្នាដែលបញ្ជាក់អោយឃើញថាជនជាប់ចោទឈ្មោះ [redacted] **សាវឡុង ហៅ** [redacted] ឈ្មោះ [redacted] **រើន** ឈ្មោះ [redacted] **ផាន់និត** ពិតជាបានរួមគំនិតគ្នាជិះតាមធាក់ម៉ូតូជនរងគ្រោះអោយដួល ហើយដណ្តើមយកម៉ូតូជនរងគ្រោះជិះចេញទៅប្រាកដមែន។

ហេតុនេះជនជាប់ចោទត្រូវទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្តបទល្មួចមានស្ថានទម្ងន់ទោសដែលមានចែងក្នុងបញ្ញត្តិមាត្រា៣៥៣ មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៦/ យល់ឃើញថាជនជាប់ចោទឈ្មោះ [redacted] **សាវឡុង** ជាមេខ្លោងក្នុងការធ្វើសកម្មភាពនេះដោយទូរស័ព្ទបញ្ជាអោយជនជាប់ចោទឈ្មោះ [redacted] **ផាន់និត** និងឈ្មោះ [redacted] **រើន** ជិះម៉ូតូឌុបគ្នាតាមធាក់ផ្តួលយកម៉ូតូរបស់ជនរងគ្រោះជិះគេចខ្លួន ក្រោយមកសមត្ថកិច្ចស្រាវជ្រាវចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] **រើន** និងឈ្មោះ [redacted] **ផាន់និត**។

៧/ ជនជាប់ចោទជានិតិជន ហើយពុំមានភស្តុតាងណាមួយបញ្ជាក់ថាមានបញ្ហាខាងស្មារតីឡើយ។

ហេតុនេះជនជាប់ចោទមានស្មារតីជានាល្អ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួន។

៨/ ការលើកឡើងរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ក្នុងសេចក្តីសន្និដ្ឋានប្តឹងសុំអំពីអង្គហេតុ និងពិរុទ្ធភាពលើជនជាប់ចោទពីបទលួចមានស្ថានទម្ងន់ទោសនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

៩/មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ផាន់និត** ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ ឈ្មោះ [redacted] **រើន** ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ ឈ្មោះ [redacted] **សាវឡុង** ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ ពីបទលួចមានស្ថានទម្ងន់ទោស (វាយឃាត់ម៉ូតូ) ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវជាតិលេខ៤ ភូមិព្រៃបឹង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ តាមបញ្ជត្តិមាត្រា៣៥៣ មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះឈ្មោះ [redacted] ចិត្រា ពុំបានចូលមកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

<u>ហេតុដូច្នេះសម្រេច</u>

១/ ផ្តន្ទាទោស៖

ក- ឈ្មោះ [redacted] **ផាន់និត** ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ

ខ-ឈ្មោះ [redacted] **រើន** ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន ០៤ (បួន)ឆ្នាំ ពីបទ: **លួចមានស្ថានទម្ងន់ទោស (វាយឃាត់ម៉ូតូ)** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវជាតិលេខ៤ ភូមិព្រៃបឹង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ តាមបញ្ជត្តិមាត្រា៣៥៣មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២/ ផ្តន្ទាទោស

-ឈ្មោះ [redacted] **សាវឡុង** ហៅ **ឡុង** ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៤ (បួនឆ្នាំ) ពីបទ: **លួចមានស្ថានទម្ងន់ទោស (វាយឃាត់ម៉ូតូ)** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវជាតិលេខ៤ ភូមិព្រៃបឹង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ តាមបញ្ជត្តិមាត្រា៣៥៣ មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣/ចេញដីកាបង្គាប់អោយចាប់ខ្លួនលើជនជាប់ចោទឈ្មោះ [redacted] **សាវឡុង** ហៅ **ឡុង** ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ យកមកទទួលទោសតាមអំណាចនៃសាលក្រមព្រហ្មទណ្ឌនេះ តាមបញ្ជត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ផាន់និត** និងឈ្មោះ [redacted] **រើន** កំពុងមុខជនជាប់ចោទឈ្មោះ [redacted] **សារឡុង** និងជនរងគ្រោះឈ្មោះ [redacted] **ចិត្រា**។

-ទុកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ	**ចៅក្រមប្រឹក្សា**	**ចៅក្រមប្រឹក្សា**	**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រា	ហត្ថលេខា	ហត្ថលេខា	ហត្ថលេខា និងត្រា
[redacted]			

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃសុក្រ ៧រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner